**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**
សំណុំរឿង រដ្ឋប្បវេណី
លេខៈ៣៨
ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ១៩៩៩
**<u>សាលដីកា</u>**
លេខៈ២៣៥
ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៤

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**
បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៤ ដោយមានសមាសភាពដូចតទៅៈ
១-ឯកឧត្តម ............ ជាប្រធាន
២-លោក ............. ជាចៅក្រមចៅក្រមរបាយការណ៍
៣-លោក ............. ជាចៅក្រម
៤-លោក ................ ជាចៅក្រម
៥-លោក ................ ជាចៅក្រម

**<u>ក្រឡាបញ្ជី</u>**
-អ្នកស្រី .............

**<u>តំណាងមហាអយ្យការ</u>**
-លោក ............. ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីការដ្ឋប្បវេណីលេខ៧៥១ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ នៃសំណុំរឿងរដ្ឋប្បវេណីលេខ១៤១ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ១៩៩៨ របស់សាលា ឧទ្ធរណ៍ រវាង

ដើមចោទឈ្មោះសស(ជាចុងបណ្តឹងសាទុក្ខ) អាយុ៥៥ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើចំការ ទីលំនៅភូមិទី១ ឃុំខ្សាម ស្រុកកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ។ ឪពុកឈ្មោះសួន (ស) ម្តាយឈ្មោះខ្លួន ហុង (ស)។

ចុងចម្លើយឈ្មោះជរ (ជាម្ចាស់បណ្តឹងសាទុក្ខ) អាយុ៥៥ឆ្នាំ ជាតិខ្មែរ មុខរបរគ្រូបង្រៀន ទីលំនៅភូមិទី១ ឃុំខ្សាម ស្រុក-ខេត្តកំពង់ឆ្នាំង ។ ឪពុកឈ្មោះមាឃ សឿង(រ)ម្តាយឈ្មោះកើត ហ៊ុន (រ) ។

**<u>កម្មវត្ថុបណ្តឹង</u>** ប្តឹងទាមទារដីភូមិ

បានឃើញបណ្តឹងសាទុក្ខលេខ៤៣៧ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ១៩៩៨ របស់លោកជរ បានប្តឹងមិនសុខចិត្តនឹងសេចក្តីសម្រេចនៃសាលដីការបស់សាលាឧទ្ធរណ៍ទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ៣៨ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ១៩៩៩ របស់តុលាការកំពូល។

តាមពាក្យបណ្ដឹងចុះថ្ងៃទី១០-១២-៩៦ របស់លោកសួន ស៊ើន ថាចំពោះដីទំនាស់ទំហំ៤,៥០ម គុណ ២ម ខ្លួនបានគ្រប់គ្រងហើយ ធ្វើតូបលក់វ៉ាន់តាំងពីឆ្នាំ១៩៧៩ រហូតដល់ឆ្នាំ១៩៩៦ ត្រូវរដ្ឋឲ្យរុះរើដេញចាំង និងដំបូល ព្រោះប៉ះពាល់សោភ័ណភាព លុះដល់ខែ៦ ឆ្នាំ១៩៩៦ ឈ្មោះមាឃ អឿង បានយកបង្គោលរបងមកបោះចំពាក់កណ្ដាលដីដោយមិនឲ្យគ្រួសារខ្លួនលក់ដូរ បានតទៅទៀត ខ្លួនបានប្ដឹងទៅមេឃុំខ្សាម ឈ្មោះមាឃ អឿង ក៏ពុំព្រមឲ្យដែរ ។ ហេតុនេះទើបខ្លួនប្ដឹងមកតុលាការដើម្បីប្ដឹងសុំទាមទារដីភូមិទំហំ៤,៥០ម គុណ ២ម ឲ្យទៅឈ្មោះមាឃ អឿង រុះរើចេញ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ១៤ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ១៩៩៨ របស់តុលាការខេត្តកំពង់ឆ្នាំ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ ៖

១-ទទួលពាក្យបណ្ដឹងរបស់ដើមចោទចុះថ្ងៃទី១០-១២-៩៦ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ តែបដិសេធចោលដោយខុស នឹងគតិច្បាប់ ។

២-ប្រគល់ដីទំហំ១១,០៥០ម$^{២}$ ខាងកើតទល់ឈ្មោះសាំង សិរិវឌ្ឍ ខាងត្បូងទល់ផ្លូវជាតិលេខ៥ ខាងលិច និងខាងជើងទល់ឈ្មោះមាន អឿង ឲ្យទៅឈ្មោះមាឃ អឿង តែមិនអនុញ្ញាតិឲ្យសាងសង់សំណង់អ្វីលើដីនោះឡើយ ។

៣-រឹបអូសប្រាក់ប្រដាប់ក្ដី គឺពន្ធចុះបញ្ជីក្ដី និងពន្ធហ្នឹង១៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០៛ ប្រាក់ចំណាយក្នុងការស៊ើបសួរ៥០០០៛ បូកសរុប៧០០០៛ ប្រាក់នេះបានកាត់យកពីដើមចោទដែលបានបង់ទុករួចហើយ កាលបើហួសឧទ្ធរណ៍បង្គាប់ឲ្យឈ្មោះសួន ស៊ើន បង់ពន្ធសមាមាត្របន្ថែមទៀតស្មើ $\frac{១x៣០០.០០០៛}{១០០}$ ស្មើ ៣០០០៛ ប្រាក់នេះដាក់ចូលថវិកាជាតិ៨០% គឺស្មើ២៤០០៛ និងបានដាក្រឡាបញ្ជីទូទាំងប្រទេស២០% គឺស្មើ៦០០៛ ។

តាមមាត្រា១,២,៥ នៃច្បាប់ភូមិបាល ចុះថ្ងៃទី១៣ ខែ១០ ឆ្នាំ១៩៩៣ ។ និងតាមលិខិតជម្រាប់របស់ក្រសួងសាធារណៈការ និងដឹងជញ្ជូនលេខ២០២១ សក៤ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ១៩៩៦ ។

សាលក្រមនេះជំនុំជំរះ ជាសាធារណៈចំពោះមុខគូក្ដី បើគូក្ដីណាមិនសុខចិត្តមានសិទ្ធិប្ដឹងឧទ្ធរណ៍រយៈពេល២ខែ តាមកំណត់ច្បាប់ ។

បានឃើញបណ្ដឹងឧទ្ធរណ៍លេខ០៤ ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ១៩៩៨ របស់លោកសួន ស៊ើន ដែលបានប្ដឹងជំទាស់នឹងសាលក្រមរដ្ឋប្បវេណីលេខ១៤ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ១៩៩៨ របស់តុលាការខេត្តកំពង់ឆ្នាំង លើសេចក្ដីសម្រេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៧៥១ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី០៦-៦៣-១៩៩៨ របស់ឈ្មោះសួន ស៊ើន ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-បដិសេធសាលក្រមរដ្ឋប្បវេណីលេខ១៤ ចុះថ្ងៃទី១២-០២-១៩៩៨ របស់តុលាការខេត្តកំពង់ឆ្នាំងចោលជាអសារបង់ ។

៣-ប្រគល់ដីទំនាស់រវាងឈ្មោះសួន ស៊ើន និងឈ្មោះជរ ស្ថិតនៅក្នុងភូមិទី១ ឃុំខ្សាម ស្រុកកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ដែលមានព្រំប្រទល់ខាងត្បូង២,១៤ម ខាងជើង២,២០ម ខាងលិច៥,២០ម និងខាងកើត៥ម មានទំហំ អេស$_{២}$ ស្មើ៥,៥៦៣៦ម$^{២}$ តាមប្លង់ចុះថ្ងៃទី១០-១២-១៩៩៧ របស់ប្រធានការិយាល័យភូមិបាលស្រុកកំពង់ឆ្នាំង ទៅឱ្យឈ្មោះសួន ស៊ើន កាន់កាប់ និងគ្រប់គ្រងជាកម្មសិទ្ធិតទៅ នៅពេលដែលសាលដីកានេះចូលជាស្ថាពរ ។

៤-សម្រេចកាត់យកប្រាក់ប្រដាប់ក្តីចំនួន១៣.០០០៛ ដែលដើមបណ្តឹងឧទ្ធរណ៍ បានបង់ទុករួចហើយ គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្មឹង២៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០៛ រង្វាន់អ្នកប្រគល់ដីកាកោះ និងអាជ្ញាធរតុលាការ១០.០០០៛ សរុប១៣.០០០៛ ។ កាលបើហួស កំណត់ប្តឹងសាទុក្ខបង្គាប់ឱ្យឈ្មោះជរ សងប្រាក់ចំនួន១៣.០០០៛ នេះទៅដើមបណ្តឹងឧទ្ធរណ៍វិញ បង្គាប់ឱ្យបង់ពន្ធសមាមាត្រមួយភាគរយលើតម្លៃដីដែលបានសម្រេចក្នុងចំណុចទី៣ នៃសាលដីកានេះគឺ៨០ភាគរយ បង់ចូលថវិការដ្ឋ និង២០ភាគរយបានជារង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ។

៥-សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូក្តី ។ បើកផ្លូវ សាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ៤៣៧ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ១៩៩៨ របស់លោកជរ បានប្តឹងមិនសុខចិត្តនិងសេចក្តីសម្រេចនៃសាលដីការបស់សាលាឧទ្ធរណ៍ទាំងមូល ។

បានឃើញសារណា ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ១៩៩៩ របស់លោកជរ ។

បានឃើញសារណាតបចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ១៩៩៩ របស់លោក សួន ស៊ើន ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ២៣២ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៩ របស់តុលាការកំពូលដែលមានអ្វីមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលបណ្តឹងសាទុក្ខលេខ៤៣៧ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ១៩៩៨ របស់លោក ជរទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២-តម្កល់សាលដីការដ្ឋប្បវេណីលេខ៧៥១ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

៣-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩.០០០៛ ដែលលោកជា បានបង់រួចហើយ គឺ :

-ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន៤.០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០៛ សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

-ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០៛ សរុប១៩.០០០៛ ។

បង្គាប់ឱ្យលោកជរ បង់ពន្ធសមាមាត្រតាមការកំណត់របស់សាលាឧទ្ធរណ៍

៤-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៩ ។

បានឃើញពាក្យបណ្តឹងរបស់ឈ្មោះជរ ចុះថ្ងៃទី០២-០៦-២០០៤ ដែលសុំបកស្រាយសាលដីកាលេខ២៣២ ចុះថ្ងៃទី២៨-១២-១៩៩៩ របស់តុលាការកំពូល ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា :

-ពាក្យបណ្តឹងរបស់លោកជរ ប្តឹងសុំឱ្យតុលាការកំពូល បកស្រាយសាលដីការដ្ឋប្បវេណីលេខ២៣២ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៩ ស្ថិតនៅក្នុងកំណត់ច្បាប់ គប្បីលើកយកមកពិនិត្យ ពិចារណា ។

- តាមសាលដីកាសាលាឧទ្ធរណ៍លេខ៧៥១ ចុះថ្ងៃទី៣០-១១-១៩៩៨ ដែលតុលាការកំពូលសម្រេចតម្កល់ទុកជាបានការនោះ ឃើញថា មានការភ័ន្តច្រឡំ ផ្នែកសំភារៈ ដែលតុលាការកំពូល អាចកែតម្រូវបាន ។

អាស្រ័យហេតុនេះ សូមក្រុមប្រឹក្សាជំនុំជំរះសម្រេចតាមច្បាប់ ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាបហើយ .

## តុលាការកំពូល

- យល់ឃើញថា ពាក្យបណ្តឹងរបស់លោកជរ ចុះថ្ងៃទី០២-០៦-២០០៤ ដែលស៊ើបកស្រាយសាលដីការបស់តុលាការកំពូលលេខ២៣២ ចុះថ្ងៃទី២៨-១២-១៩៩៩ ធ្វើឡើងត្រឹមត្រូវតាមច្បាប់ តុលាការកំពូលអាចលើកយករឿងនេះមកជំនុំជំរះ និងបកស្រាយបាន ។

- យល់ឃើញថា សាលដីការបស់សាលាឧទ្ធរណ៍ ដែលតុលាការកំពូលសម្រេចតម្កល់ទុកជា បានការនោះ បានបញ្ជាក់ថា ដីដែលប្រគល់ឱ្យឈ្មោះសួន ស៊ើន នោះមានព្រំប្រទល់ខាងត្បូង២,១៤ម. ខាង

ជើង២,២០ម ខាងលិច៥,២០ម និងខាងកើត៥ម ប៉ុន្តែបែរជាសរសេរថាមានទំហំ$S_2$=៥.៥៦៣៦ម² ទៅវិញ ។ បើគិតតាមជ្រុងនីមួយ គឺមានទំហំ $S_t=S_1+S_2$ =៥,៤៨៦៨ម²+៥,៥៦៣៦ម²=១១,០៥០៤ម²ពុំមែន ស្មើនឹង $S_2$=៥,៥៦៣៦ម²ទេ (តាមគំនូសប្លង់ចុះថ្ងៃទី១០-១២-៩៧) របស់ការិយាល័យភូមិបាលស្រុកកំពង់ឆ្នាំង។ ដូច្នេះដោយសារកំហុស នេះជាកំហុសផ្នែកសំភារៈ គប្បីតុលាការកំពូលធ្វើការកែតម្រូវទំហំដីទំនាស់ ពី $S_2$=៥.៥៦៣៦ម² មក $S_t=S_1+S_2$= ១១,០៥០៤ម²ជាវិញ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ២៣២ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៩ របស់តុលាការកំពូលដែលបានសម្រេចសេចក្ដីមកនេះ មានការខុសឆ្គងផ្នែកសំភារៈប្រាកដមែន ។

**ចដូច្នេះវិនិច្ឆ័យសេមក្ដី**

១-ទទួលបណ្ដឹងសុំបកស្រាយសាលដីកា ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០០៤ របស់លោកជា រុំ ទុកជាត្រឹមត្រូវតាមច្បាប់ ។

២-កែតម្រូវសាលដីការដ្ឋប្បវេណីលេខ២៣២ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៩ របស់តុលាការកំពូល ត្រង់ចំណុចទី៣ នៃសាលដីការសាលឧទ្ធរណ៍លេខ៧៥១ ចុះថ្ងៃទី៣០-១១-៩៨ ពីទំហំ$S_2$=៥.៥៦៣៦ម² ទៅជាទំហំ $S_t=S_1+S_2$= ១១,០៥០៤ម² វិញ ។

៣-សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៤។